Seattle Office of Sustainability & Environment

**ដាក់ពាក្យសុំមូលនិធិយុត្តិធម៌បរិស្ថានរបស់ទីក្រុង Seattle**

ការិយាល័យនិរន្តរភាព និងបរិស្ថាន (OSE) របស់ទីក្រុងស៊ីថល មានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសថា មូលនិធិយុត្តិធម៌បរិស្ថាន **ឥឡូវនេះកំពុងតែទទួលយកពាក្យសុំ។** ឆ្នាំនេះ មានជម្រើសថវិកាចំនួនពីរប្រភេទ។ ជម្រើសទីមួយផ្តល់ជំនួយចាប់ពី $10,000 ដល់ $40,000 ដោយមានមូលនិធិសរុបចំនួន $250,000។ ជម្រើសទីពីរផ្តល់ជំនួយចាប់ពី $40,001 ដល់ $90,000 ដោយមានមូលនិធិសរុបចំនួន $750,000។ មូលនិធិទាំងនេះគឺដើម្បីគាំទ្រគម្រោងការដែលផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារភាពអយុត្តិធម៌បរិស្ថាននិងអាកាសធាតុ រួមមានទាំងជនជាតិស្បែកខ្មៅ ជនជាតិដើមភាគតិច ប្រជាជនដែលមិនមែនជនជាតិស្បែកស ជនអន្តោប្រវេសន៍ ជនភៀសខ្លួន អ្នកដែលមានប្រាក់ចំណូលទាប យុវវ័យ និងមនុស្សចាស់ជរា។ **ថ្ងៃផុតកំណត់នៃការដាក់ពាក្យសុំគឺ ម៉ោង 5 ល្ងាច (PT) ថ្ងៃពុធទី 26 ខែកក្កដា។**

ឱកាសដាក់ពាក្យសុំមូលនិធិនេះគឺបើកចំហសម្រាប់កុលសម្ព័ន្ធ និងអង្គការកុលសម្ព័ន្ធ អង្គការមិនរកប្រាក់ចំណេញ និងក្រុមសហគមន៍ដែលធ្វើការជាមួយសហគមន៍របស់ពួកគេដើម្បីលើកកម្ពស់ភាពយុត្តិធម៌បរិស្ថាននិងអាកាសធាតុ។ ប្រភេទនៃគម្រោងការដែលមានសិទ្ធិទទួល រួមមានទាំង ប៉ុន្តែមិនត្រឹមតែកំណត់ចំពោះសិល្បៈនិងការនិទានរឿង ការអប់រំសហគមន៍ ការកសាងសមត្ថភាពអង្គការ និងសហគមន៍ ការត្រៀមខ្លួនសម្រាប់ការប្រែប្រួលអាកាសធាតុ ការកសាងជំនាញនិងការបណ្តុះបណ្តាលទាក់ទងហើយនិងការងារស្តារគុណភាពបរិស្ថានឡើងវិញ (ការងារបៃតង)* និងការធ្វើផែនការនិងចក្ខុវិស័យសហគមន៍។

ប្រសិនបើអ្នកចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមអំពីមូលនិធិនេះ ចង់ពិភាក្សាអំពីគំនិតបើកគម្រោងការ ឬការដាក់ពាក្យសុំ អ្នកអាចអនុវត្តតាមជំហានដូចខាងក្រោម៖

- ចុះឈ្មោះ នៅទីនេះ ដើម្បីពិភាក្សាតាមទូរសព្ទរយៈពេល 20 នាទីជាមួយសមាជិកនៃក្រុមការងាររបស់យើង។
    - សូមប្រើទម្រង់បែបបទដើម្បីស្នើសុំសេវាកម្មបកប្រែភាសា។
- ចូលរួមវគ្គផ្តល់ព័ត៌មានតាមអនឡាញ៖
    - ថ្ងៃពុធ ទី 21 ខែមិថុនា ម៉ោង 12-1:30 យប់ - ចុះឈ្មោះនៅទីនេះ
    - សូមផ្ញើអ៊ីមែលមកយើងតាមរយៈ *equityenviro@seattle.gov* ដើម្បីស្នើសុំសេវាកម្មបកប្រែភាសាទុកជាមុន។
- ចូលរួមវគ្គផ្តល់ព័ត៌មានដោយផ្ទាល់៖
    - ថ្ងៃអង្គារ ទី 27 ខែមិថុនា ម៉ោង 6-7:30 យប់ - ចុះឈ្មោះនៅទីនេះ
    - **ទីតាំង៖** បណ្ណាល័យសាធារណៈទីក្រុង Columbia បន្ទប់ប្រជុំ Columbia

        - 4721 Rainier Ave S, Seattle, WA 98118
    - សូមផ្ញើអ៊ីមែលមកយើងតាមរយៈ *equityenviro@seattle.gov* ដើម្បីស្នើសុំសេវាកម្មបកប្រែភាសាទុកជាមុន។

យើងក៏អាចឆ្លើយសំណួរតាមរយៈអ៊ីម៉ែលបានដែរ equityenviro@seattle.gov ។ សូមចូលទៅកាន់ **seattle.gov/environment/ejfund** ដើម្បីស្វែងយល់បន្ថែមនិងដាក់ពាក្យសុំ។

* សម្រាប់គោលបំណងនៃមូលនិធិកម្មវិធី EJ ការងារស្តាគុណភាពបរិស្ថានឡើងវិញ ត្រូវបានកំណត់ថាជាការងារដែលមានគោលបំណងដោះស្រាយឬកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។